សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខៈ ១៦១ /១៩ ស.អ.ក

# សេចក្តីប្រកាសព័ត៌មាន

**សហព័ន្ធស្រូវអង្ករកម្ពុជា** (ស.អ.ក) មានកិត្តិយសសូមជម្រាបជូនសមាជិក សមាជិកា និងសាធារណៈជនមេត្តាជ្រាបថា កាលពីថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ នៅភោជនីយដ្ឋាន គ្រឿង ហ្គាឌិន សហព័ន្ធស្រូវអង្ករកម្ពុជា បានរៀបចំកម្មវិធីប្រកួតអង្ករល្អនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឧកញ៉ា ហ៊ិន ឡាក់** ប្រធានក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា អាណត្តិទី៣ និងក្រោមកិច្ចសហប្រតិបត្តិការជាមួយសមាគមចុង- ភៅកម្ពុជា ដែលមានសមាសភាពគណៈកម្មការចុងភៅទាំងខ្មែរ និងបរទេស ចំនួន៩រូប និងក្រុមហ៊ុនពិនិត្យគុណភាពអង្ករអន្តរជាតិចំនួនពីរក្រុមហ៊ុនមានសមាសភាពចំនួន៤រូបគឺ ក្រុមហ៊ុនអូអិមអាយស៊ី (OMIC) និងក្រុមហ៊ុនស៊ីស៊ីអាយស៊ី (CCIC)។

ការរៀបចំកម្មវិធីប្រកួតអង្ករនេះ គឺមានក្រុមហ៊ុនចំនួន ៩ក្រុមហ៊ុន និងអង្គការសហគមន៍ចំនួន ១ ដែលបានប្រគល់នូវផលិតផលអង្ករជាសំណាកចំនួន ១៨សំណាក ក្នុងចំណោមប្រភេទអង្ករ ៣ប្រភេទ ដែលក្នុងនោះ ប្រភេទអង្ករក្រអូបប្រណិត ចំនួន ៦សំណាក ប្រភេទអង្ករក្រអូប ចំនួន ៧សំណាក និងប្រភេទអង្ករសគ្រាប់វែង ចំនួន ៥សំណាក។

នៅក្រោមការវិនិច្ឆ័យយ៉ាងម៉ត់ចត់ពី គណៈកម្មការវាយតម្លៃ និងដាក់ពិន្ទុ ចំនួន ១៤រូប ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដើម (សពោះ ភាពបាក់ រូបរាង ទំហំ ពណ៌ ប្រវែង ភាពភ្លឺរលោង និងក្លិន) និងលក្ខណៈសម្បត្តិក្រោយពេលចម្អិន (ភាពភ្លឺរលោង ភាពស្អិតម្សួត រសជាតិ ក្លិន និងភាពងាយក្នុងការញ៉ាំ) បានលទ្ធផលដូចខាងក្រោម៖

១- ជ័យលាភីលើប្រភេទអង្ករក្រអូបប្រណិត (Premium Aromatic Rice) ស្ថិតនៅក្នុងម៉ាកអង្ករ «**ម្លិះអង្ករ**» ត្រូវបានទៅលើ៖

- ចំណាត់ថ្នាក់លេខ ១ : ក្រុមហ៊ុន បេតាម៉រ (Betamore)
- ចំណាត់ថ្នាក់លេខ ២ : ក្រុមហ៊ុន ស៊ីកនេតឈ័រ អហ្វអេស៊ា (Signatures of Asia Co.,Ltd)
- ចំណាត់ថ្នាក់លេខ ៣ : ក្រុមហ៊ុន បាយ័ន សៀរាល (Bayon Cereal)

២- ជ័យលាភីលើប្រភេទអង្ករក្រអូប (Fragrant Rice) ពូជសែនក្រអូប ត្រូវបានទៅលើ៖

- ចំណាត់ថ្នាក់លេខ ១ : ក្រុមហ៊ុន បាត់ដំបងរ៉ាយស៍ អ៊ិនវេសមេន ខូអិលធីឌី
- ចំណាត់ថ្នាក់លេខ ២ : ក្រុមហ៊ុន អេមរុ រាយស៍(ខេមបូឌា) ខូលអិលធីឌី (AMRU Rice)
- ចំណាត់ថ្នាក់លេខ ៣ : ក្រុមហ៊ុន បាយ័ន សៀរាល (Bayon Cereal)

៣- ជ័យលាភីលើប្រភេទអង្ករស គ្រាប់វែង (Long Grain White Rice) ត្រូវបានទៅលើ៖

- ចំណាត់ថ្នាក់លេខ ១ : ក្រុមហ៊ុន វង្ស ប៊ុនហេង អិមផត អ៊ិចផត ខូ អិលធីឌី
- ចំណាត់ថ្នាក់លេខ ២ : អង្គការសហគមន៍អភិវឌ្ឍន៍សង្គមកម្ពុជា
- ចំណាត់ថ្នាក់លេខ ៣ : ក្រុមហ៊ុន បេតាម៉រ (Betamore)

ថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩
**សហព័ន្ធស្រូវអង្ករកម្ពុជា**

CAMBODIA RICE FEDERATION